00273793

ការ/N: ① 127

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Royaume du Cambodge

Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
26 / 01 / 2009
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Bureau des Co-juges d'instruction**

**Office of the Co-Investigating Judges**

**សំណុំរឿងព្រហ្មទណ្ឌ**

**Dossier pénal/Criminal Case File**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Instruction/Investigation**

**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចស្ដីពីការមើលឯកសារសំណុំរឿង ដោយជនជាប់ឃុំ

# Ordonnance sur l'accès au dossier par les détenus

# Order on Access to the Case File by Detainees

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្ដីពី អ.វ.ត.ក.")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា និងជនត្រូវចោទដទៃទៀត**

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក.

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: K. K. Ratanak



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax:+855(0)23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញវិធាន ២២(៣) និងវិធាន ៥៦(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. (វិធានផ្ទៃក្នុង)

បានឃើញវិធាន ៩(២១) និងវិធាន ២៣ នៃវិធានសម្រាប់គ្រប់គ្រងការឃុំខ្លួនជន ដែលរង់ចាំការជំនុំជម្រះ ឬបណ្ដឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិធានស្ដីពីការគ្រប់គ្រងមន្ទីរឃុំឃាំង របស់ អ.វ.ត.ក.)

បានឃើញសំណើសុំការបញ្ជាក់របស់ក្រុមមេធាវីការពារក្ដី អៀង ធីរិទ្ធ អំពីវិធានដែលនៅជាធរមានទាក់ទងនឹងការទទួលលិខិតថតចម្លងនៃឯកសារសំណុំរឿងរបស់ជនត្រូវចោទ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៨ (A228)

បានឃើញសំណើសុំរបស់ក្រុមមេធាវីការពារក្ដី នួន ជា ក្នុងការចូលមើលសំណុំរឿង ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៨ (A239)

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នៅថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ ២០០៨ ក្នុងសេចក្ដីសម្រេចទាក់ទងនឹងសំណុំរឿង ០០១/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស. សហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដីធ្វើការផ្ដល់ឱ្យជនជាប់ឃុំ នូវឯកសារថតចម្លងនៃសំណុំរឿង ដោយមានលក្ខខណ្ឌកំហិតមួយចំនួនដែល តម្រូវឱ្យសមាជិករបស់ក្រុមមេធាវីការពារក្ដី ធ្វើការផ្ដល់ឯកសារដោយផ្ទាល់ដៃ និងយកត្រឡប់មកវិញនៅរៀងរាល់ល្ងាច[1]។ អនុលោមតាមសេចក្ដីសម្រេចនេះ មេធាវីការពារក្ដីជនជាប់ឃុំឃាំង នៅក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស. ត្រូវបានអនុញ្ញាតទទួលបានក្នុងលក្ខណៈបណ្ដោះអាសន្ននូវផលប្រយោជន៍ប្រហាក់ប្រហែលគ្នានឹងនេះដែរ។

---

[1] 001/A54/I **អនុស្សរណៈផ្ញើជូនទៅនាយកមន្ទីរឃុំឃាំង អ.វ.ត.ក.** ថ្ងៃទី ០៨ កុម្ភៈ ២០០៨

២. នៅថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៨ ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ បានស្នើសុំឱ្យមានការបំភ្លឺអំពីវិធានដែលកំពុងអនុវត្ត ទាក់ទងនឹងការទទួលលិខិតថតចម្លងនៃឯកសារសំណុំរឿងរបស់ជនត្រូវចោទ (A228)

៣. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យមានការផ្តល់ឱ្យកូនក្តីរបស់ខ្លួន នូវឯកសារសំណុំរឿង (A239)

៤. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានស្នើសុំយោបល់របស់ប្រធានមន្ទីរឃុំឃាំងទាក់ទងនឹងទីកន្លែង និងធនធានបុគ្គលិកក្នុងការរក្សាទុកឯកសារសំណុំរឿងថតចម្លង (A228/2-239/2)។

៥. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៨ ប្រធានមន្ទីរឃុំឃាំងបានឆ្លើយតបថា ដោយសារហេតុផលទីកន្លែង និងហានិភ័យនៃអគ្គីភ័យ មន្ទីរឃុំឃាំងមិនមានលទ្ធភាពក្នុងការរក្សាទុកនូវឯកសារថតចម្លងទាំងអស់នៃសំណុំរឿងនោះទេ ប៉ុន្តែអាចឱ្យមានការតម្លើងទូរតូចមួយដែលអាចចាក់សោរបាន ដើម្បីតំកល់ឯកសារខ្លះៗបាន (A/239/2/1)។

## ច្បាប់ដែលត្រូវអនុវត្ត

៦. មាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧) មិនបានអនុញ្ញាតឱ្យមេធាវីធ្វើការផ្តល់ដល់កូនក្តីរបស់ខ្លួន នូវឯកសារថតចម្លងនៃសំណុំរឿង នៅក្នុងក្របខណ្ឌនៃនីតិវិធីធម្មតា នៅចំពោះមុខតុលាការកម្ពុជានោះទេ៖ *"...មេធាវីអាចអានលិខិតនៃសំណុំរឿងឱ្យកូនក្តីខ្លួនស្តាប់។ ផ្ទុយទៅវិញ មេធាវីមិនអាចឱ្យលិខិតថតចម្លងពីលិខិតនៃសំណុំរឿង ដល់កូនក្តីរបស់ខ្លួនបានឡើយ"* ។

00273796

ឯកសារ/ឯះ ៖ ០១២៧

៧. វិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ចែងអំពីគោលការណ៍ថា *"សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ មានសិទ្ធិគ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង ក្រោមការឃ្លាំមើលរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត"* ។ ប៉ុន្តែអនុវិធាន ២២(៣ និង ៤) មិនមានចែងពីការហាមឃាត់ណាមួយក្នុងការមើលឯកសារសំណុំរឿងដោយផ្ទាល់ដោយជនត្រូវចោទទេ ប៉ុន្តែគ្រាន់តែរំលឹកថា នៅក្នុងការបំពេញមុខងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង និងច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈវិជ្ជាជីវៈមេធាវី និងបទដ្ឋាន និងក្រមសីលធម៌ផ្សេងទៀត ដែលត្រូវអនុវត្តនៅក្នុងការប្រកបវិជ្ជាជីវៈនេះ។

**អំណះអំណាងរបស់ភាគី**

៨. ក្រុមមេធាវីការពារក្តី អៀងធីរិទ្ធ បានធ្វើការកត់សម្គាល់អំពី *"វត្តមាននៃវិធាន និងការអនុវត្តន៍ដែលផ្ទុយគ្នាចំពោះបញ្ញត្តិ ដែលទាក់ទងទៅនឹងការថតចម្លងផ្តល់ឲ្យជនត្រូវចោទនូវឯកសារ សំណុំរឿង"* ហើយបានស្នើសុំការបញ្ជាក់អំពីគោលនយោបាយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនឹងសិទ្ធិរបស់ជនត្រូវចោទជាលក្ខណៈអន្តរជាតិ ដែលមានចែងនៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ក្រុមមេធាវីការពារក្តីបានបញ្ជាក់ថា ការទទួលបានឯសារសំណុំរឿង "ជាប្រចាំ" នឹងសម្រួលដល់កូនក្តីរបស់ខ្លួនក្នុងការរៀបចំការពារខ្លួន។

៩. មេធាវីការពារក្តី នួន ជា បានយកទឡ្ហីករណ៍នៃសំណើរបស់ អៀង ធីរិទ្ធ មកធ្វើជាការយោង ដោយបន្ថែមថាការមើលឯកសារសំណុំរឿងជាទៀងទាត់ និង"លទ្ធផលការងាររបស់មេធាវីការពារក្តី" ច្រើនជាងមុន ជៀសជាងការរៀបចំដែលមានលក្ខណៈជាបណ្តោះអាសន្ននាពេលបច្ចុប្បន្ន គឺជាការចាំបាច់សម្រាប់កូនក្តីរបស់ខ្លួនក្នុងការ *"ចូលរួមប្រកបដោយទៅផ្លែផ្កា"* នៅក្នុងកិច្ចស៊ើបសួរ។ មេធាវីបានស្នើសុំឲ្យមាន *"បន្ទប់សុវត្ថិភាពបម្រុងទុកមួយ"* ដែលមានផ្ទុកនូវ *"ឯកសារថតចម្លងសំណុំរឿងលេខ ០០២ ទាំងមូល"* សម្រាប់ការប្រើប្រាស់របស់ នួន ជា នៅអំឡុងពេលនៃម៉ោងធ្វើការ ព្រមទាំងចង់ឲ្យដាក់ទូរសម្រាប់ដាក់ឯកសារមួយនៅក្នុងបន្ទប់ឃុំឃាំងកូនក្តីខ្លួន ដែលអាចអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនអាចមើលឯកសារទាំងនេះ ដោយគ្មានការកំហិត។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## ហេតុផលនៃសេចក្ដីសម្រេច

១០. ដោយអនុវត្តតាមមាត្រា ២៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតកត់សំគាល់ឃើញថា ចរិតលក្ខណៈនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ភាពស្មុគស្មាញនៃសំណុំរឿង និងចំនួនឯកសារដ៏ច្រើនលើសលប់ ដែលជាប់ពាក់ព័ន្ធនឹងដំណើរការនីតិវិធីរបស់ អ.វ.ត.ក. បង្កើតឲ្យមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តន៍ជាក់ស្ដែងនៃវិធាន ៥៥(៦)៖ ជាពិសេសការដែលមិនមានចែងហាមឃាត់ច្បាស់លាស់អំពីការចូលមើលសំណុំរឿងនៅក្នុងវិធាន ២២(៣) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. បានឆ្លុះបញ្ចាំងអំពីតម្រូវការនៃភាពទន់ភ្លន់មួយ គឺការអនុវត្តន៍តឹងរឹងនៃបទប្បញ្ញត្តិនៃមាត្រា ១៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនត្រូវបានគិតថាមានលក្ខណៈសមរម្យទេនៅក្នុងបរិបទនេះ។

១១. រឿងក្ដីនៅក្នុងតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ទាក់ទិននឹងចូលមើលសំណុំរឿងរបស់ជនត្រូវចោទ មានការវិវឌ្ឍន៍ទៅតាមពេលវេលា។ បន្ទាប់ពីបានពិចារណាឃើញថា ការកំហិតចំពោះមេធាវីរបស់ជនត្រូវចោទ ក្នុងការមើលសំណុំរឿង មិនបានបំពានលើមាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស[2]រួចមក (គឺវាដូចនឹងមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្ដីពី សិទ្ធិពលរដ្ឋ និងនយោបាយដែរ) វាមានការកើនឡើងនៃទំនោរទទួលស្គាល់ថា សិទ្ធិរបស់ជនត្រូវចោទក្នុងការចូលរួមក្នុងការការពារខ្លួន និងគោលការណ៍ស្មើភាពជាមួយនឹងអយ្យការ ទាមទារឲ្យមានការមើលភស្ដុតាង "ដោយផ្ទាល់ និងគ្រប់គ្រាន់" នៅក្នុងកម្រិតមួយពីសំណាក់ជនត្រូវចោទដោយខ្លួនឯង ដូច្នេះ *"អ្នកស្នើសុំ អាចកំណត់បានពីឧបត្ថម្ភករណ៍ ដែលទាក់ទិននឹងការការពារខ្លួន ក្រៅពីអ្វីដែលមេធាវីរបស់ខ្លួន បានលើកឡើង"* [3]។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស បានបំភ្លឺថា ការមើល "គ្រប់គ្រាន់" ត្រូវតែបានវាយតម្លៃ

---

[2] សូមអាន ជាឧទាហរណ៍ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស (ECHR), *Kremzow ទល់នឹង ប្រទេសអូទ្រីស* សាលក្រម អង្គជំនុំជម្រះ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣ ពាក្យស្នើសុំ លេ. ១២៣៥០/៨២ និង ECHR, *Kamasinski ទល់នឹង ប្រទេសអូទ្រីស* សាលក្រម អង្គជំនុំជម្រះ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៨៩ ពាក្យស្នើសុំ លេ. ៩៧៨៣/៨២។

[3] ECHR, *Ocanlan ទល់នឹង ប្រទេសទួរគី* សាលក្រម អង្គជំនុំជម្រះធំ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ ពាក្យស្នើសុំ លេ. ៤៦២២១/១៩៩ កថា ១៤៣។

00273798



*"ដោយគិតទៅដល់ចរិតលក្ខណៈនៃឯកសារដែលមានសម្រាប់ជនជាប់ឃុំ ចំនួន និងសារៈសំខាន់របស់វា ក្នុងការវាយតម្លៃពីភាពត្រឹមត្រូវតាមច្បាប់នៃការឃុំខ្លួន"*[4] ។

១២. ការវិវត្តន៍នៅក្នុងយុត្តិសាស្ត្រនៃតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស ត្រូវបានឆ្លុះបញ្ចាំងដោយច្បាប់នៅក្នុងប្រទេសបារាំង (ដែលនីតិវិធីមានលក្ខណៈសមស្របជាមួយ អ.វ.ត.ក) ដែលទទួលស្គាល់សិទ្ធិមួយចំនួនរបស់ជនជាប់ឃុំក្នុងការមើលសំណុំរឿង នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ[5]។

១៣. នៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ទោះបីជាចរិតលក្ខណៈនៃ "សំណុំរឿង" នៅដំណាក់កាលមុនពេលជំនុំជម្រះ មិនអាចប្រៀបធៀបឱ្យត្រូវគ្នានឹងកិច្ចស៊ើបសួរនៅ អ.វ.ត.ក ក៏ដោយ ក៏មានការអនុវត្តន៍ដូចគ្នា គឺអនុញ្ញាតឱ្យជនជាប់ឃុំរក្សាច្បាប់ថតចម្លងនៃសំណុំរឿងរបស់ពួកគេនៅក្នុងបន្ទប់ឃុំឃាំង[6]។

១៤. ម្យ៉ាងវិញទៀត ចំពោះករណីនេះ ការមើលសំណុំរឿងបានទូលំទូលាយជាងមុន អាចឱ្យជនត្រូវចោទអនុវត្តទៅតាមសេចក្តីត្រូវការចាំបាច់ ដែលត្រូវបានទទួលស្គាល់ដោយដីការបស់សហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងការបកប្រែ[7] *"ដោយចូលរួមចំណែកដល់ការបំពេញសេចក្តីត្រូវនៃការបកប្រែ"* តាមរយៈការប្រើប្រាស់ចំណេះដឹងផ្នែកភាសារបស់ខ្លួន។

---

[4] ECHR, *Migon ទល់នឹង ប្រទេសប៉ូឡូញ* សាលក្រម ផ្នែកទី ៤ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០២ ពាក្យស្នើសុំ ល. ២៤២៤៤/៩៤។ សូមអានផងដែរ ECHR, *Garcia Alva ទល់នឹង ប្រទេសអាល្លឺម៉ង់* សាលក្រម ផ្នែកទី ១ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ពាក្យស្នើសុំ ល. ២៣៥៤១/៩៤ និង ECHR, *Lietzow ទល់នឹង ប្រទេសអាល្លឺម៉ង់* សាលក្រម ផ្នែកទី ១ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០១ ពាក្យស្នើសុំ ល. ២៤៤៧៩/៩៤។ ។

[5] សូមអានមាត្រា ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ២០០៧។

[6] ជាឧទាហរណ៍ សូមអាន វិធាន ១១ និង វិធាន ៤១ នៃវិធានស្តីពី ការសួរសុខទុក្ខ និងការទំនាក់ទំនងរបស់ ICTY ។

[7] A190 ដីកាទាក់ទិននឹងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៨



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

១៥. ដោយហេតុផលទាំងអស់នេះហើយ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា វាជាការចាំបាច់ ដែលត្រូវបង្កើតឲ្យមានគោលការណ៍ទូទៅមួយ ដើម្បីកំណត់អំពីកម្រិតសមស្របក្នុងការមើលសំណុំរឿង សម្រាប់ជនត្រូវចោទ ដែលជាប់ឃុំទាំងអស់ ដោយគិតពីសិទ្ធិរបស់មេធាវី និងស្ថានភាពនៅក្នុងមន្ទីរឃុំឃាំងនាពេលបច្ចុប្បន្ន។ ក្នុងគោលដៅនេះ សហចៅក្រមស៊ើបអង្កេត បានដកស្រង់គំនិតចេញពីវិធាននីតិវិធី និងទម្លាប់អនុវត្តន៍ទាំងឡាយដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ ដោយគិតពីការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រព័ន្ធច្បាប់ដែលមានវិធាននីតិវិធីប្រហាក់ប្រហែលគ្នា និងពីស្ថានភាពជាក់ស្តែងនៃមន្ទីរឃុំឃាំងដែលបានបង្កើតឡើង។

១៦. នៅក្នុងការអនុវត្តន៍ជាក់ស្តែង ដូចប្រធានមន្ទីរឃុំឃាំង បានលើកឡើងនៅក្នុងលិខិតរបស់ខ្លួន (A239/2/1) និងដូចបានបញ្ជាក់ច្បាស់នៅអំឡុងពេលនៃការចុះពិនិត្យមន្ទីរឃុំឃាំងដោយបុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត រួមដំណើរជាមួយនឹងមន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំងនោះ គឺមិនមានបន្ទប់ដែលមានទំហំធំអាចរក្សាទុកសំណុំរឿងទាំងមូលបានទេ។ លើសពីនេះទៀត វាមានការលំបាកសម្រាប់បុគ្គលិករបស់ផ្នែកគ្រប់គ្រងតុលាការ ក្នុងការធ្វើបច្ចុប្បន្នភាពឯកសារសំណុំរឿង និងមិនអាចរក្សាឯកសារទាំងនោះបានល្អគ្មានអ្នកណាប៉ះពាល់ ដោយមិនមានវត្តមានមនុស្សនៅប្រចាំការជាអចិន្ត្រៃយ៍ដើម្បីពិនិត្យមើលពីការយកចេញ ចូល នៃឯកសារដែលត្រូវប្រើប្រាស់នោះទេ ដោយសារវាមិនស្ថិតនៅក្រោមអំណាច ឬសមត្ថកិច្ចរបស់បុគ្គលិកមន្ទីរឃុំឃាំងទេ។

១៧. ហេតុដូច្នេះ ការអនុវត្តន៍នាពេលបច្ចុប្បន្ន ដែលតម្រូវឲ្យសមាជិកនៃក្រុមមេធាវីការពារក្តីយកឯកសារទាំងនេះ ទៅមន្ទីរឃុំឃាំង និងយកត្រឡប់មកវិញ គឺជាវិធីតែមួយគត់ដែលអាចធ្វើបាន ដើម្បីធានាពីការទទួលខុសត្រូវ និងបូរណភាពនៃសំណុំរឿង។ ដោយសារមន្ទីរឃុំឃាំង ស្ថិតនៅជិតនឹងការិយាល័យអចិន្ត្រៃយ៍របស់ក្រុមមេធាវីនោះ ការទាមទារដូច្នេះនឹងមិនបង្កជាការលំបាកដែលមិនអាចទទួលយកបានពីសំណាក់ក្រុមមេធាវីទេ។ លើសពីនេះទៀត វិធានសម្រាប់មន្ទីរឃុំឃាំងដែលទើបត្រូវបានអនុម័តនាពេលថ្មីៗនេះ បានចែងយ៉ាងលំអិតពីនីតិវិធីសម្រាប់ក្រុមមេធាវីដែលមានបំណងផ្តល់ឯកសារទៅឲ្យកូនក្តីរបស់ខ្លួន អនុលោមទៅតាមអនុវិធាន ៩(២១ និង២៣)។

**ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតសម្រេចដូចខាងក្រោម÷**

- **យល់ព្រម** ឲ្យសហមេធាវីជនជាប់ឃុំទាំងអស់ ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ជូនដល់កូនក្តីរបស់ខ្លួននូវឯកសារថតចម្លងនានា នៃសំណុំរឿង និងសិទ្ធិក្នុងការទាក់ទងចាំបាច់សម្រាប់រៀបចំការការពារក្តី និងជាអ្នកយកឯកសារទាំងនេះត្រឡប់មកវិញដោយខ្លួនឯង ឬតាមរយៈសមាជិកនៃក្រុមរបស់ខ្លួន អនុលោមទៅតាមនីតិវិធី ដែលមានចែងក្នុងវិធានសម្រាប់មន្ទីរឃុំឃាំង ជាពិសេសអនុវិធាន ៩(២១ និង២៣)។

- **អនុញ្ញាត** ឲ្យជនជាប់ឃុំម្នាក់ៗ អាចទុកឯកសារទាំងនេះនៅក្នុងបន្ទប់របស់ខ្លួនសម្រាប់រយៈពេលយូរទៅតាមការចាំបាច់ និងប្រើប្រាស់វាទាំងនៅក្នុងបន្ទប់និងនៅពេលជួបមេធាវីរបស់ខ្លួន ប៉ុន្តែឯកសារដែលទុកទាំងអស់ក្នុងពេលតែមួយ មិនត្រូវឲ្យលើសពីចំណុះផ្ទុកនៃទូរសម្រាប់ដាក់ឯកសារអាចចាក់សោរបាន ដែលនឹងត្រូវដាក់នៅតាមបន្ទប់ឃុំឃាំងនីមួយៗនោះទេ។

- **ស្នើ** ឲ្យប្រធានមន្ទីរឃុំឃាំង ពិភាក្សាជាមួយនឹងមន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំង និងអង្គភាពគាំពារការការពារក្តី ដើម្បីអនុវត្តដីកានេះ រួមទាំងការផ្តល់ទូរសម្រាប់ដាក់ឯកសារដែលអាចចាក់សោរបានទៅឲ្យជនជាប់ឃុំម្នាក់ៗផង ហើយជូនដំណឹងមកសហចៅក្រមស៊ើបអង្កេតវិញអំពីលទ្ធផលនៃការអនុវត្តដីកានេះ។

- **ស្នើជាបន្ថែម** ឲ្យប្រធានមន្ទីរឃុំឃាំង ធានាថាឯកសារទាំងនេះត្រូវបានរក្សាទុកយ៉ាងមានសុវត្ថិភាព នៅពេលមានការមកសួរសុខទុក្ខពីអ្នកដទៃដែលមិនមែនជាសមាជិកនៃក្រុមមេធាវីការពារក្តី។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

- ស្នើ ឲ្យមន្ត្រីទំនាក់ទំនងមន្ទីរឃុំឃាំង ធានាថា រាល់សេចក្តីណែនាំទាំងឡាយចំពោះក្រុមមេធាវីការពារក្តី ទាក់ទិននឹងការចូលជួបកូនក្តីរបស់ខ្លួននៅក្នុងមន្ទីរឃុំឃាំង ត្រូវបានកែសម្រួលក្នុងករណីចាំបាច់ ដើម្បីឲ្យស្របតាមដីកានេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.